អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សំនួរនិងចម្លើយស្តីអំពីសិទ្ធិមនុស្ស

www.hoksavann.org

ថ្ងៃទី២៣ កញ្ញា ២០១២



យើងសូមអនុញ្ញាតដកស្រង់យកអត្ថបទរបស់គណៈកម្មាធិការប្រមូលឯកសារស្តីពីកម្ពុជា ដែលបានផ្សាយកាលពីថ្ងៃ១០ធ្នូ១៩៩១ ផ្សំជាមួយទស្សនៈរបស់យើង ដោយយល់ឃើញថា អត្ថបទនេះមានប្រយោជន៍សំខាន់ណាស់សំរាប់ប្រទេសកម្ពុជា ដោយនៅទន់ខ្សោយខាងការគោរពសិទ្ធិមនុស្ស ជាពិសេសអ្នកដឹកនាំរដ្ឋ យកទៅពិចារណានិងអនុវត្ត ។

១- សំនួរ ៖ អ្វីទៅដែលហៅថាសិទ្ធិមនុស្ស ?

ចម្លើយ ៖ សិទ្ធិមនុស្សគឺជាក្បួនវិន័យ សំរាប់ឲ្យអាជ្ញាធររដ្ឋនីមួយៗគោរពតាម ក្នុងការគ្រប់គ្រងពលរដ្ឋ ។ ក្នុងនោះមានវិន័យហាមប្រាមមិនឲ្យរដ្ឋាភិបាល ឬអាជ្ញាធរនយោបាយប្រព្រឹត្តប្រឆាំងនឹងពលរដ្ឋ ដូចជាទារុណកម្ម ចាប់ខ្លួនឃុំឃាំងដោយមិនសមហេតុផល ខាឃាំងមិនឲ្យពលរដ្ឋប្រើសេរីភាពក្នុងការនិយាយស្តី បញ្ចេញមតិ រួមប្រជុំ និងបង្កើតជាសមាគមជាដើម...

ម្យ៉ាងវិញទៀត សិទ្ធិមនុស្សគឺជាក្បួនវិន័យសំរាប់ឲ្យរដ្ឋាភិបាល ឬអាជ្ញាធរនយោបាយបំពេញភារកិច្ចជូនប្រជាពលរដ្ឋខ្លួន ដោយផ្តល់ការអប់រំថ្នាក់បឋមសិក្សា ការថែទាំសុខភាព ផ្តល់ថ្ងៃសំរាក និងពេលវេលាសំរាក និងលំហែកាយអំពីកិច្ចការជាដើម... ប្រសិនបើគេមានសម្បត្តិធមធានគ្រប់គ្រាន់ ។

២- សំនួរ ៖ សិទ្ធិមនុស្សចេញមកពីណា ?

ចម្លើយ៖ជាទូទៅសិទ្ធិមនុស្សផ្អែកទៅលើសេចក្តីប្រាថ្នា«សេចក្តីថ្លៃថ្នូរជាមនុស្ស»ឬរក្សា«ភាពដែលពុំអាចរំលោភបាននៃជីវិតមនុស្ស» ដែលមានចែងនៅក្នុងមហាសាសនានានាក្នុងពិភពលោក ដែលនៅក្នុងនោះមានរួមទាំងព្រះពុទ្ធសាសនាផង ។

«សិទ្ធិ» គឺជាវត្ថុដែលមនុស្សត្រូវការជាចាំបាច់ ដើម្បីដឹកនាំជីវិតរស់នៅជា «មនុស្សពេញលេញ» ។ បើគ្មាន «សិទ្ធិ» ទេ មនុស្សទាំងពួងរស់នៅមិនខុសគ្នាអំពីសត្វប៉ុន្មានទេ ហើយជួនកាលទៀតពុំអាចរស់នៅបានផង ។

៣- សំនួរ ៖ តើសិទ្ធិមនុស្សជាតម្រានៃព្រះពុទ្ធសាសនាឬ ?

ចម្លើយ ៖ ជាការប្រាកដណាស់ ធម៌ព្រះពុទ្ធមានភាពទូលំទូលាយ ហើយគ្របដណ្តប់ទៅលើសិទ្ធិមនុស្សទាំងមូល ហើយសិទ្ធិមនុស្សជាភាគមួយធំនៃការរស់នៅតាមបែបពុទ្ធសាសនា ។

សិទ្ធិមនុស្សចែងអំពីការគិតគូរដ៏ត្រឹមត្រូវ, ការប្រព្រឹត្តដ៏ត្រឹមត្រូវ រវាងបុរស ស្ត្រី ហើយនិងកុមារ ព្រមទាំងនៅក្នុងសង្គមនិងរដ្ឋដែលគេរស់នៅ ជាពិសេសរវាងអ្នកដឹកនាំនិងអ្នកនៅក្រោមបង្គាប់, រវាងរដ្ឋាភិបាលនិងពលរដ្ឋ ។ ព្រះពុទ្ធសាសនាមិនត្រឹមតែគិតគូរអំពីមារយាទល្អត្រឹមត្រូវរបស់បុគ្គលនិងសង្គមប៉ុណ្ណោះទេ ថែមទាំងគិតទៅដល់ការប្រព្រឹត្តដ៏ត្រឹមត្រូវរវាងមនុស្សនិងសត្វលោកឯទៀតៗ ហើយនិងរវាងមនុស្សនិងធម្មជាតិផងដែរ ។

ព្រះពុទ្ធសាសនាចែងអំពីលោកីយ៍មួយ ដែលមិនមានការឈឺចាប់ រីឯសិទ្ធិមនុស្សវិញ គឺគិតត្រឹមតែធ្វើយ៉ាងណាកុំឲ្យមនុស្សទទួលការឈឺចាប់ ដែលបណ្តាលមកអំពីការប្រព្រឹត្តពុំគប្បី ឬខុសតម្រាពីសំណាក់អាជ្ញាធររដ្ឋាភិបាល ។

៤- សំនួរ ៖ អ្នកណាជាអ្នកកំណត់សិទ្ធិមនុស្ស និងកំណត់អំពីបទរំលោភសិទ្ធិមនុស្ស ?

ចម្លើយ ៖ គំនិតដែលបង្កើតឲ្យមានបទវិន័យ សំរាប់ឲ្យភ្នាក់ងាររដ្ឋាភិបាលប្រព្រឹត្តតាម ជាគំនិតតាមបែបបូរាណ ដែលដូចគ្នាទៅនឹងបទវិន័យសំរាប់ឲ្យពលរដ្ឋសាមញ្ញអនុវត្តតាមអញ្ចឹងដែរ ។ ឧទាហរណ៍ ៖ កាលពីសម័យព្រះពុទ្ធជាម្ចាស់គង់នៅ ព្រះអង្គទ្រង់បានចែងជាក្រិត្យវិន័យ ជាមាគ៌ានៃការប្រព្រឹត្តសំរាប់ស្តេច ដែលមានឈ្មោះថា «ទសរាជធម៌» ។

នៅក្នុងលោកីយ៍បច្ចុប្បន្ននេះ ក្បួនវិន័យនិងស្តង់ដានៃច្បាប់សិទ្ធិមនុស្ស បានត្រូវកំណត់ឡើងដោយរដ្ឋាភិបាលជាច្រើនក្នុងពិភពលោក ដែលជួបប្រជុំគ្នានៅអង្គការសហប្រជាជាតិ ដើម្បីចរចារកឯកភាពទៅលើភារកិច្ច ដែលរដ្ឋាភិបាលគួរបំពេញជូនពលរដ្ឋខ្លួន និងអ្វីៗទៀតដែលគេពុំត្រូវធ្វើប្រឆាំងនឹងពលរដ្ឋ ។

(នៅមានត)